ក្រសួង ដ.ន.ស.
ចូល
លេខ 6921
ចុះថ្ងៃ 5.12.24.
ម៉ោង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៨០ អនក្រ.បក

# អនុក្រឹត្យ

# ស្ដីពី

# គោលការណ៍និងបទប្បញ្ញត្តិនៃការកំណត់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីគោលការណ៍និងបទប្បញ្ញត្តិនៃការកំណត់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ក្នុងគោលបំណងដើម្បីធានាឱ្យមានការឯកភាពគ្នាជាស្តង់ដារួម ក្នុងការប្រើលេខកូដសម្គាល់ភូមិសាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## គោលការណ៍នៃការកំណត់និងទម្រង់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៣ .-**

លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំតាមគោលការណ៍និងទម្រង់ ដូចខាងក្រោម៖

- រាជធានី ខេត្ត ត្រូវមានលេខកូដសម្គាល់២ខ្ទង់
- ក្រុង ស្រុក ខណ្ឌ ត្រូវមានលេខកូដសម្គាល់៤ខ្ទង់
- ឃុំ សង្កាត់ ត្រូវមានលេខកូដសម្គាល់៦ខ្ទង់
- ភូមិ ត្រូវមានលេខកូដសម្គាល់៨ខ្ទង់។

ទម្រង់គំរូលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ក្នុងករណីមានការបង្កើតខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិថ្មី នោះលេខកូដសម្គាល់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិបង្កើតថ្មី ត្រូវកំណត់តាមលំដាប់បន្ទាប់ពីលេខកូដសម្គាល់ចុងក្រោយនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដែលមានស្រាប់ ស្របតាមគោលការណ៍និងទម្រង់លេខកូដសម្គាល់ ដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

ក្នុងករណីមានការលុបចោលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ លេខកូដសម្គាល់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិដែលត្រូវបានលុបចោលនោះ មិនត្រូវបានយកទៅប្រើទៀតឡើយ។ លេខកូដសម្គាល់ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិចំណុះខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលបានលុបចោល ត្រូវកំណត់ជាថ្មីតាមលំដាប់បន្ទាប់ពីលេខកូដសម្គាល់ចុងក្រោយនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដែលបានទទួល ស្របតាមគោលការណ៍និងទម្រង់លេខកូដសម្គាល់ ដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ក្នុងករណីមានការកែប្រែព្រំប្រទល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ការកំណត់លេខកូដសម្គាល់ ត្រូវអនុវត្តដូចខាងក្រោម៖

- ក្នុងករណីមានការកែប្រែព្រំប្រទល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដោយធ្វើការកាត់យកភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ឬខណ្ឌនៃភូមិសាស្ត្ររាជធានី ខេត្ត នោះភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ឬខណ្ឌដែលបានកាត់នោះ ត្រូវកំណត់លេខកូដសម្គាល់ថ្មីតាមលំដាប់បន្ទាប់ពីលេខកូដសម្គាល់ចុងក្រោយនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ស្របតាមគោលការណ៍និងទម្រង់លេខកូដសម្គាល់ ដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ
- ក្នុងករណីមានការកែប្រែព្រំប្រទល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដោយធ្វើការបំបែក នោះលេខកូដសម្គាល់ភូមិសាស្ត្រចាស់ត្រូវបានលុបចោល។ ភូមិសាស្ត្រដែលត្រូវបំបែក ត្រូវកំណត់លេខកូដសម្គាល់ថ្មីតាមលំដាប់បន្ទាប់ពីលេខកូដសម្គាល់ចុងក្រោយនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ស្របតាមគោលការណ៍និងទម្រង់លេខកូដសម្គាល់ ដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ក្នុងករណីមានការកែប្រែឈ្មោះខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ លេខកូដសម្គាល់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិដែលត្រូវបានកែប្រែឈ្មោះថ្មីនោះ ត្រូវរក្សាទុកដដែល។

## ជំពូកទី៣
## ការដាក់ឱ្យប្រើ ការកែសម្រួល និងការលុបលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៨ .-**

ការដាក់ឱ្យប្រើ ការកែសម្រួល និងការលុបលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៩ .-**

រាល់ឯកសារផ្លូវការ ដែលមានភ្ជាប់លេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដែលមានមុនការដាក់ឱ្យប្រើលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្របតាមមាត្រា៨នៃអនុក្រឹត្យនេះ ត្រូវបន្តប្រើហូតដល់អស់សុពលភាពឬមានការផ្លាស់ប្តូរថ្មី។



9

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ ធ្នូ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

អភិសន្តិបណ្ឌិត **ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៨០ អនក្រ.បក ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២៤
ស្ដីពីគោលការណ៍និងបទប្បញ្ញត្តិនៃការកំណត់លេខកូដសម្គាល់រាជធានី ខេត្ត
ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា

## ទម្រង់គំរូលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

គំរូលេខកូដសម្គាល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ មានទម្រង់ដូចខាងក្រោម៖

- រាជធានី ខេត្ត ត្រូវមានលេខកូដសម្គាល់២ខ្ទង់ ដោយចាប់ផ្ដើមពី ក១ ទៅ ក២ រាប់ពីឆ្វេងទៅស្ដាំ
- ក្រុង ស្រុក ខណ្ឌ ត្រូវមានលេខកូដសម្គាល់៤ខ្ទង់ ដោយចាប់ផ្ដើមពី ក១ ទៅ ក៤ រាប់ពីឆ្វេងទៅស្ដាំ
- ឃុំ សង្កាត់ ត្រូវមានលេខកូដសម្គាល់៦ខ្ទង់ ដោយចាប់ផ្ដើមពី ក១ ទៅ ក៦ រាប់ពីឆ្វេងទៅស្ដាំ
- ភូមិ ត្រូវមានលេខកូដសម្គាល់៨ខ្ទង់ ដោយចាប់ផ្ដើមពី ក១ ទៅ ក៨ រាប់ពីឆ្វេងទៅស្ដាំ។




**ឧទាហរណ៍៖** លេខកូដសម្គាល់ខេត្ត ស្រុក ឃុំ និងភូមិ នៅខេត្តបន្ទាយមានជ័យ មានទម្រង់ដូចខាងក្រោម៖

- លេខកូដ២ខ្ទង់ដំបូងរាប់ពីឆ្វេងទៅស្ដាំគឺលេខ 01 ជាលេខកូដសម្គាល់ខេត្តបន្ទាយមានជ័យ
- លេខកូដ៤ខ្ទង់ដំបូងរាប់ពីឆ្វេងទៅស្ដាំគឺលេខ 0102 ជាលេខកូដសម្គាល់ស្រុកមង្គលបុរី
- លេខកូដ៦ខ្ទង់ដំបូងរាប់ពីឆ្វេងទៅស្ដាំគឺលេខ 010201 ជាលេខកូដសម្គាល់ឃុំបន្ទាយនាង
- លេខកូដ៨ខ្ទង់រាប់ពីឆ្វេងទៅស្ដាំគឺលេខ 01020101 ជាលេខកូដសម្គាល់ភូមិអូរធំ។

